00373661

ឯកសារ: D180/4

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 06 / 08 / 2009
ម៉ោង (Time/Heure): 14:35
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៦ ខែ សីហា ឆ្នាំ ២០០៩

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

សម្ងាត់
CONFIDENTIAL
CONFIDENTIEL
09/09/2009

សាធារណៈ
PUBLIC
26/01/2010

---

**ចម្លើយតបរបស់លោក អៀង សារី នៅនឹងសំណើសុំអោយបំពេញកិច្ចស៊ើបសួររបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ**

**និង សំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់**

---

**ដាក់ដោយ៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ផ្ញើជូន៖**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមទៅតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងរបស់ អវតក ("វិធាន") តទៅនេះសូមដាក់ជូននូវចម្លើយតបទៅនឹងសំណើសុំអោយបំពេញកិច្ចស៊ើបសួររបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ ("សំណើសុំ")។ សំណើសុំនេះអះអាងថា៖ (១) "គោលការណ៍ច្បាប់អន្តរជាតិបានចែងយ៉ាងច្បាស់ថា ការប្រព្រឹត្តជាទូទៅ និងជាប្រព័ន្ធនៃការបាត់ខ្លួនមនុស្សដោយបង្ខំ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" [1]។ (២) អវតក "តាមរយៈសហចៅក្រមស៊ើបអង្កេត តុលាការនេះមានតួនាទីធ្វើការស៊ើបអង្កេត នូវការកើតមានឡើងនូវការបាត់ខ្លួនមនុស្សដោយបង្ខំ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[2]" ខណៈដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជា *វិធានអាជ្ញាបញ្ញា*[3] *(jus cogens)* ហើយថា (៣) ការបាត់ខ្លួនមនុស្សដោយបង្ខំគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលឋិតនៅក្រោមយុត្តាធិការរបស់ អវតក[4] តាមកិច្ចព្រមព្រៀងបង្កើត អវតក[5] ឬ ជាទម្រង់មួយនៃ "អំពើអមនុស្សធម៌ផ្សេងៗ[6]" ដែលឋិតនៅក្រោមច្បាប់បង្កើតតុលាការនេះ[7] ។ សូមស្នើដោយក្តីគោរពថា សំណើនេះខកខានមិនបានផ្តល់នូវការគាំទ្រគ្រប់គ្រាន់សម្រាប់ការអះអាងទាំងនេះឡើយ។ ម្យ៉ាងវិញទៀត សំណើនេះខកខានយ៉ាងច្បាស់ក្រឡែតមែនទែនក្នុងការពន្យល់ម្តោះហើយមិនអោយជឿបាន ថាហេតុអ្វី៖ (១) ភាគីដើមបណ្តឹងរដ្ឋប្បវេណីគួរត្រូវបានអនុញ្ញាតអោយធ្វើសំណើទៅសហចៅក្រមស៊ើបអង្កេត ("កសចស") សុំអោយបំពេញកិច្ចស៊ើបសួរនូវអង្គហេតុដែលមិនស្ថិតនៅក្នុងវិសាលភាពនៃឧក្រិដ្ឋកម្ម ដែលគេចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ដោយរំលោភបំពានយ៉ាងជាក់ស្តែងលើវិធានផ្ទៃក្នុង និងថាហេតុអ្វី (២) ការបាត់ខ្លួនមនុស្សដោយបង្ខំគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលចងកាតព្វកិច្ចកម្ពុជា នៅក្នុងអំឡុងឆ្នាំ ១៩៧៥-៧៩។ ឈរលើមូលដ្ឋានទាំងពីរនេះ សំណើនេះគឺមិនត្រឹមត្រូវឡើយ។

---

[1] សំណើសុំ កថាខណ្ឌ ៥ ។

[2] *ដូចយោងខាងលើ* កថាខណ្ឌ ៧ ។

[3] *ដូចយោងខាងលើ* ។

[4] *ដូចយោងខាងលើ* កថាខណ្ឌ ១០ ។

[5] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង")។

[6] សំណើសុំ កថាខណ្ឌ ១៩ ដល់ ២២ ។

[7] ច្បាប់ស្តីពីការបង្កើតអោយមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើវិសោធនកម្ម ហើយប្រកាសអោយប្រើកាលពីថ្ងៃទី ២៧ តុលា ២០០៤ ("ច្បាប់បង្កើត អវតក")។

## I. សង្ខេបនៃអំណះអំណាង

១. មេធាវីការពារក្តីនឹងបង្ហាញថា៖

ក. ការបាត់ខ្លួនមនុស្សដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនឋិតនៅក្នុងយុត្តាធិការរបស់ អវតក ឡើយ

ខ. មិនមានទំនាស់ខាងផ្នែកយុត្តាធិការទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិរវាងកិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក នេះឡើយ ។ បើសិនជាមានទំនាស់បែបនេះមែន ច្បាប់បង្កើត អវតក ត្រូវមានអានុភាពជាង

គ. ការបាត់ខ្លួនមនុស្សដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សនៅក្រោមច្បាប់កម្ពុជា ឬក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅអំឡុងឆ្នាំ ១៩៧៥-៧៩ ឡើយ

ឃ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនមែនជា *វិធានអាជ្ញាបញ្ញា (jus cogens)* ហើយគ្មាន *បទដ្ឋានដាច់អហង្ការ (peremtory norm)* ដើម្បីចោទប្រកាន់បទល្មើសទាំងនោះឡើយ

ង. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនអាចអនុវត្តដោយផ្ទាល់នៅក្នុងតុលាការក្នុងស្រុកបានឡើយ

ច. ជាជម្រើសផ្សេង ការដាក់ព្រំដែនកម្រិតលើយុត្តាធិការដោយ អវតក ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺជាការស្របច្បាប់ និងត្រូវតែអនុវត្ត។

## II. អង្គច្បាប់

### ក. ការស៊ើបអង្កេតបឋមរបស់ កសព និងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម

២. ក្រោមវិធានផ្ទៃក្នុង ៥៩(១) "[ការ]ចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងឡាយណា ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ អាចធ្វើឡើងបានតាមការផ្តួចផ្តើមរបស់សហព្រះរាជអាជ្ញាតែប៉ុណ្ណោះ ទោះបីជាការសម្រេចចិត្តដោយឯកឯង ឬដោយផ្អែកតាមពាក្យបណ្តឹងក៏ដោយ"។ វិធាន ៥៩(៤) ចែងបន្ថែមទៀតថា៖

> [ពាក្យ]បណ្តឹងទាំងនេះមិនអាចជាប្រភពផ្តើមធ្វើការចោទប្រកាន់ ជាស្វ័យប្រវត្តិអំពីបទឧក្រិដ្ឋបានទេ ហើយសហព្រះរាជអាជ្ញាត្រូវធ្វើការសម្រេចដោយឆន្ទានុសិទ្ធិ ថាតើត្រូវតម្កល់បណ្តឹងទុកឥតចាត់ការ ឬ បញ្ចូលបណ្តឹងនោះទៅក្នុងរឿងដែលការស៊ើបអង្កេត

បឋមកំពុងដំណើរការ ឬ បើកការស៊ើបអង្កេតបឋមថ្មី ឬបញ្ជូនពាក្យបណ្តឹងនោះដោយផ្ទាល់ទៅសហចៅក្រមស៊ើបអង្កេត។

៣. តាមវិធាន ៥០ កសព អាច "ដឹកនាំការស៊ើបអង្កេតបឋមដើម្បីកំណត់ភស្តុតាង ដែលបង្ហាញអំពីការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះ" ហើយប្រសិនបើ កសព "មានហេតុផលជឿថា ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញបានកើតមានពិត សហព្រះរាជអាជ្ញាត្រូវបើកការស៊ើបសួរ ដោយបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទៅសហចៅក្រមស៊ើបអង្កេត" ។

៤. ក្រោមវិធាន ៥៥(៣) កសព អាចដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម បន្ទាប់ពីបញ្ជូនសេចក្តីសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរទៅ កសចស រួចមកប្រសិនបើ "មានលេចចេញនូវអង្គហេតុថ្មី"[8]។

## ខ. សំណើសុំអោយបំពេញកិច្ចស៊ើបសួរ

៥. អង្គច្បាប់ទាក់ទងនឹងប្រភេទ និងវិសាលភាពនៃសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ មានបញ្ជាក់យ៉ាងពិស្តារនៅក្នុងសំណើលើកទីមួយរបស់លោក អៀង សារី សុំឱ្យបំពេញកិច្ចស៊ើបសួរ[9] ដែលមានបានដាក់បញ្ចូល មានត្រឹមតែជាសេចក្តីយោងប៉ុណ្ណោះ។

## គ. ច្បាប់សារធាតុដែលអនុវត្តនៅ អវតក

៦. មាត្រា ១ នៃកិច្ចព្រមព្រៀងចែងនូវគោលបំណងរបស់ខ្លួនថាជាការកំណត់៖

អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភទៅលើអនុសញ្ញា

---

[8] វិធានផ្ទៃក្នុង ៥៣(១)

[9] *សំណុំរឿង អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើរបស់លោក អៀង សារី សុំអោយបំពេញកិច្ចស៊ើបសួរលើកទីមួយ ចុះថ្ងៃទី ២០ មីនា ២០០៩ កថាខណ្ឌ ២-១៨ ("សំណើស៊ើបសួរទីមួយរបស់ អៀង សារី")។*សូមមើលផងដែរ សំណុំរឿង អៀង សារី* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស សំណើរបស់លោក អៀង សារី សុំអោយបំពេញកិច្ចស៊ើបសួរលើកទីបី ចុះថ្ងៃទី ២១ មេសា ២០០៩ កថាខណ្ឌ ៩-១១ ។

អន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩។

៧. យុត្តាធិការរបស់ អវតក ត្រូវបានកំណត់ដោយមាត្រា ១ និង មាត្រា ២ នៃច្បាប់បង្កើត អវតក ដែលចែងថា អវតក ត្រូវបានបង្កើតដើម្បី "ជំនុំជម្រះ ... ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើ ... ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ..." [10]។

៨. ទាំងកិច្ចព្រមព្រៀង និងច្បាប់បង្កើត អវតក ផ្តល់និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ មាត្រា ៩ នៃកិច្ចព្រមព្រៀងចែងថា អវតក មានយុត្តាធិការលើ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ១៩៩៨"។ ផ្ទុយទៅវិញ មាត្រា ៥ នៃច្បាប់បង្កើត អវតក ចែងពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថាជា "អំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើជនស៊ីវិលដោយមូលហេតុ ជាតិនយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"។

៩. គ្មានបទបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀង ឬ វិធាន ស្តែងអោយឃើញពីការបញ្ញត្តិជាក់លាក់អោយមានទំនាស់រវាងវិធានទាំងពីរនេះឡើយ។

## III. ភាពអាចទទួលយកបាននៃសំណើសុំ អោយបំពេញកិច្ចស៊ើបសួរ

១០. មិនមានការចែងអំពីការបាត់ខ្លួនមនុស្សដោយបង្ខំ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ("ដីកាសុំស៊ើបសួរ") ដែលធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញាកាលពីថ្ងៃទី ១៨ កក្កដា ២០០៧ ប្រឆាំងនឹង នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ និង ឌុច[11]។ កសព បានទទួលស្គាល់ជា*សាធារណៈ*ថា ឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់នៅក្នុងដីកាសុំស៊ើបសួរ ត្រូវ"បានប្រព្រឹត្តឡើងជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួមដែលបង្កើតបានជាប្រព័ន្ធមួយមិនស្របច្បាប់ និងរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា ព្រមទាំងការធ្វើទុក្ខបុកម្នេញទៅលើក្រុមគោលដៅ

---

[10] សូមមើលលេខយោងទី ៧ ខាងលើ ។ (គូសបញ្ជាក់បន្ថែម)

[11] *រឿងក្តី អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ចុះថ្ងៃទី ១៨ កក្កដា ២០០៧ ។ ឌុច ត្រូវបានបំបែកចេញពីសំណុំតាមរយៈដីកាសម្រេចចុះថ្ងៃទី ១៩ កញ្ញា ២០០៧។ *សូមមើល* ការវិវឌ្ឍន៍នៃរឿងក្តីរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១ វិច្ឆិកា ២០០៧ នៅពេលដែលសាធារណៈជនត្រូវបានជូនដំណឹងថា "កាលពីថ្ងៃទី ១៩ កញ្ញា ២០០៧ [កសចស] បានសម្រេចចេញដីកាបំបែកសំណុំរឿងរបស់ ឌុច ដើម្បីធានាការគ្រប់គ្រងយុត្តិធម៌ល្អ"។

00373666



ផ្សេងៗដែលកំណត់ទុកជាមុន"[12]។ កសព ក៏បានបញ្ជាក់ផងដែរថា ដីកាសុំស៊ើបសួរ រួមបញ្ចូលនូវ "អង្គហេតុខុសៗគ្នាចំនួន ២៥ ស្ថានភាពដែលមានជាអាទិ៍៖ ឃាតកម្ម ការធ្វើទារុណកម្ម ការជម្លៀសដោយបង្ខំ ការឃុំឃាំងដោយខុសច្បាប់ ការបង្ខំអោយធ្វើពលកម្ម ព្រមទាំងការធ្វើទុក្ខបុកម្នេញលើសាសនា នយោបាយ និងជនជាតិភាគតិច[13]" សម្រាប់ជនទាំងឡាយដែល ក.ស.ព បានកំណត់ និងបង្ហាញឈ្មោះជនសង្ស័យចំនួន ៥ រូប ដែលគេចោទថា "បានប្រព្រឹត្ត បានជួយ បានជំរុញអោយមានបទឧក្រិដ្ឋទាំងនោះ និង/ឬ មានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្មទាំងនោះ"[14]។ កសព <u>មិនបាន</u>ធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមអនុលោមទៅតាមវិធាន៥៥(៣) ដែលត្រូវរួមបញ្ចូលនូវឧក្រិដ្ឋកម្មដែលចោទប្រកាន់នៃការបាត់ខ្លួនមនុស្សដោយបង្ខំ[15]។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មដែលចោទប្រកាន់នៃការបាត់ខ្លួនមនុស្សដោយបង្ខំ <u>មិនបាន</u>បង្កើតបានជាផ្នែកមួយនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០២ នេះឡើយ ដែលសំណុំរឿងនេះត្រូវបានកម្រិតត្រឹមតែ "អង្គហេតុនានាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម"[16]។ ហេតុដូច្នេះ សំណើនេះគឺ "មិនមានភាពចាំបាច់អោយមានការបំពេញកិច្ចស៊ើបសួរ"ទេ[17] ដោយហេតុថាកិច្ចស៊ើបសួរបច្ចុប្បន្នត្រូវបានគេកម្រិតរួចទៅហើយ។ ហេតុដូចនេះ សំណើនេះមិនអាចទទួលយកបានទេ។

១១. វិធានផ្ទៃក្នុងចែងពីនីតិវិធីដើម្បីផ្តើមអោយមានការស៊ើបអង្កេតអំពើឧក្រិដ្ឋ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតអោយដាក់បណ្តឹងទាក់ទងនឹងការបាត់ខ្លួនមនុស្សដោយបង្ខំទៅ កសព ដែលជាអ្នក "ត្រូវធ្វើការសម្រេចដោយឆន្ទានុសិទ្ធិ[របស់ខ្លួន] ថាតើត្រូវតម្កល់បណ្តឹងទុកឥតចាត់ការ ឬបញ្ចូលបណ្តឹងនោះទៅក្នុងរឿងដែលការស៊ើបអង្កេតបឋមកំពុងដំណើរការ ឬបើកការស៊ើប

---

[12] *សូមមើល* សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៨ កក្កដា ២០០៧ ទំព័រ ៣ ("សេចក្តីប្រកាសរបស់ ក.ស.ព")។

[13] *អត្ថបទយោងខាងលើ* ទំព័រ ៤។

[14] *អត្ថបទយោងខាងលើ* ទំព័រ ៥។

[15] កសព បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរតាមបទបញ្ញត្តិនេះ ដែលមិនទាក់ទងនឹងការបាត់ខ្លួនមនុស្សដោយបង្ខំឡើយ។ *សូមមើលរឿងក្តី អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមរបស់ កសព ទាក់ទងនឹងមណ្ឌលសន្តិសុខភូមិភាគឧត្តរ ចុះថ្ងៃទី ២៦ មីនា ២០០៨ ។

[16] វិធាន ៥៥(២) (គូសបញ្ជាក់បន្ថែម) ។

[17] វិធាន ៥៥(១០) ។

អង្កេតបឋមថ្មី ឬបញ្ជូនពាក្យបណ្តឹងនោះដោយផ្ទាល់ទៅសហចៅក្រមស៊ើបអង្កេត" [18]។ ដោយឈរលើមូលដ្ឋាននៃពាក្យបណ្តឹងនេះ កសព អាចចេញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម ដែលត្រូវពន្លាតយុត្តាធិការនៃការស៊ើបសួររបស់ កសចស ។ ការដាក់ពាក្យបណ្តឹងនេះ <u>មិនអាច</u> "ជាប្រភពផ្តើមធ្វើការចោទប្រកាន់ ជាស្វ័យប្រវត្តិអំពីបទឧក្រិដ្ឋបានទេ" [19]។ នេះគឺជាប្រព័ន្ធនៃការផ្តើមការស៊ើបអង្កេតអំពើឧក្រិដ្ឋ ដែលជ្រើសរើសជាក់ច្បាស់ដោយ អវតក តាមរយៈវិធានផ្ទៃក្នុង។ ភាគីដើមបណ្តឹងរដ្ឋប្បវេណី មិនមានសិទ្ធិគេចវេសវិធានផ្ទៃក្នុងដោយដាក់នូវសំណើនានាអោយមានការស៊ើបសួរបន្ថែមទៅលើអំពើឧក្រិដ្ឋ និងអង្គហេតុដែលមិនស្ថិតនៅក្នុងវិសាលភាពនៃដីកាសុំស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមដែលធ្វើដោយ កសព ឡើយ។

## IV. សំណើសុំបន្ថែមចំនួនទំព័រដែលបានកំណត់

១២. ចំនួនទំព័រដែលបានកំណត់ដើម្បីធ្វើការឆ្លើយនឹងឯកសារនានាដែលដាក់នៅចំពោះមុខ កសចស គឺ ១៥ ទំព័រ[20]។ សំណើនេះលើកឡើងនូវបញ្ហាស្មុគស្មាញទាក់ទងនឹងយុត្តាធិការរបស់ អវតក នីតិវិធីស៊ើបសួររបស់ អវតក និងថានៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលចោទប្រកាន់នៃការបាត់ខ្លួនមនុស្សដោយបង្ខំ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ កាលពីជាង ៣០ឆ្នាំមុន។ រឿងនេះបង្កើតបានជា "កាលៈទេសៈលើកលែង"[21] ដែលស្រដៀងគ្នានឹងករណីទាំងឡាយដែលបណ្តាលអោយ កសចស អនុញ្ញាតតាមសំណើកាលពីលើកមុនមួយសុំអោយបន្ថែមចំនួនទំព័រដែលបានកំណត់[22]។ ហេតុដូច្នេះ មេធាវីការពារក្តីស្នើសុំថា ការបន្ថែមចំនួនទំព័រដ៏តិចតួចទៅលើចំនួនទំព័រជាក់ស្តែងពី ១៥ ទៅ ១៧ ទំព័រ។

## V. អង្គច្បាប់

---

[18] វិធាន ៥៩(៥) ។

[19] *ដូចយោងខាងលើ* (គូសបញ្ជាក់បន្ថែម)។

[20] មាត្រា ៥.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វ.៤ ចុះថ្ងៃទី ៥ មិថុនា ២០០៩ ។

[21] *ដូចយោងខាងលើ* មាត្រា ៥.៤ ។

[22] *រឿងក្តី អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ ចុះថ្ងៃទី ២ ធ្នូ ២០០៨ ។

## ក. ការបាត់ខ្លួនមនុស្សដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនស្ថិតនៅក្រោមយុត្តាធិការរបស់ អវតក ក្រោមច្បាប់បង្កើត អវតក

១៣. ច្បាប់បង្កើត អវតក មិនបានបង្កើតអោយមានទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ឬឧក្រិដ្ឋកម្មនានាឡើយ។ ច្បាប់នេះត្រឹមតែកំណត់យុត្តាធិការលើបទល្មើស (subject-matter) យុត្តាធិការលើពេលវេលា និងយុត្តាធិការលើបុគ្គល របស់ អវតក ។ ដូចដែលទទួលស្គាល់ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីថា មាត្រា ៥ នៃច្បាប់បង្កើត អវតក មិនបាន "រាយឈ្មោះការបាត់ខ្លួនមនុស្សដោយបង្ខំជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនោះទេ"[23]។ មាត្រានេះរាយឈ្មោះអំពើនានាដូចជា "ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើអោយទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា"។ ហេតុដូច្នេះ ដោយមានចេតនាដកចេញជាក់ស្តែងនូវការបាត់ខ្លួនមនុស្សដោយបង្ខំ ពីយុត្តាធិការរបស់ខ្លួន អវតក ត្រូវបានរារាំងមិនអោយធ្វើការស៊ើបអង្កេត និងវិនិច្ឆ័យទោសជនត្រូវចោទនានាចំពោះបទល្មើសដែលចោទប្រកាន់នេះពីក្នុងសំណុំរឿង ០០២ ។

១៤. ជាជម្រើសផ្សេងពីនេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា អវតក មានយុត្តាធិការលើបទល្មើសនៃការបាត់ខ្លួនមនុស្សដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមប្រភេទ "អំពើអមនុស្សធម៌ផ្សេងៗ" ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់បង្កើត អវតក[24]។ ប្រភេទនៃអំពើអមនុស្សធម៌ត្រូវបានបង្កើតឡើងមុនគេនៅក្នុងធម្មនុញ្ញតុលាការណូរ៉ឹមប៊ើក (មាត្រា ៦(គ)) និងក្រោយមកត្រូវបានចែងជាថ្មីឡើងវិញនៅក្នុងលិខិតូបករណ៍អន្តរជាតិមួយចំនួន រួមមានលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("តុលាការ ICTY")[25] រ្វាន់ដា ("តុលាការ ICTR")[26] និងតុលាការពិសេសសម្រាប់សៀរ៉ាលេអូន ("តុលាការ SCSL")[27] ។ ដោយអនុវត្តនូវគោលគំនិតនេះ អង្គជំនុំជម្រះសាលាដំបូង ICTR នៅក្នុងរឿងក្តី Akayesu បានយល់ឃើញថា បញ្ជីរាយឈ្មោះអំពើនានាមានចែងក្នុងមាត្រា ៣ គឺមិនទាន់អស់ឡើយ ហើយថា "អំពើណាមួយដែលមានលក្ខណៈ និងចារិកជាអមនុស្សធម៌ អាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

---

23 សំណើសុំ កថាខណ្ឌ ១០ ។

24 សំណើសុំ កថាខណ្ឌ ១៩-២២ ។

25 មាត្រា ៥ លក្ខន្តិកៈតុលាការ ICTY ។

26 មាត្រា ៣ លក្ខន្តិកៈតុលាការ ICTR ។

27 មាត្រា ២ លក្ខន្តិកៈតុលាការ SCSL ។

ដោយហេតុថាធាតុផ្សំដទៃផ្សេងទៀតត្រូវបានបំពេញ" [28]។ អំពើទាំងនេះត្រូវរួមបញ្ចូលអំពើទាំងឡាយណាដែលមាន "ធ្ងន់ធ្ងរប្រដូចប្រៀបគ្នា Comparable seriousness" និង មាន "ទម្ងន់ស្រដៀងគ្នា comparable gravity" ទៅនឹងអំពើនានាផ្សេងទៀតដែលមានចែងនៅក្នុងមាត្រា៣[29]។ ឃ្លាដែលថា "អំពើអមនុស្សធម៌ផ្សេងៗ" ទំនងជាមិនត្រឹមត្រូវក្នុងន័យអោយស្របទៅនឹងគោលការណ៍នៃភាពជាក់លាក់ (specificity) ដែលចែងថា "វិធានព្រហ្មទណ្ឌដាច់ខាតត្រូវមានភាពជាក់លាក់តាមដែលអាចធ្វើទៅបាន" [30]។

១៥. នៅក្នុងរឿងក្ដី Kupreskić អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញថា ការបាត់ខ្លួនដោយបង្ខំស្ថិតនៅក្រោមប្រភេទ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[31]។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងរឿងក្ដី Kupreskić អង្គជំនុំជម្រះសាលាដំបូង បានផ្អែកទៅលើឯកសារដែលចុះកាលបរិច្ឆេទក្រោយយុត្តាធិការលើអាជ្ញាយុកាលនៃពេលវេលារបស់ អ.វ.ត.ក នៅក្នុងការគាំទ្រលើផ្នែកអង្គហេតុនេះ[32]។ មិនមានការគាំទ្រចំពោះសេចក្ដីអះអាងដែលថា ការបាត់ខ្លួនដោយបង្ខំត្រូវបានចាត់ទុកថាបង្កើតជា អំពើអមនុស្សធម៌ផ្សេងទៀតឡើយនៅមុនកាលបរិច្ឆេទនេះ។

**ខ. មិនមានទំនាស់ណាមួយនៃយុត្តាធិការស្ដីអំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រវាងកិច្ចព្រមព្រៀង និងច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញឡើយ។ ប្រសិនបើមានទំនាស់បែបនោះ ច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ ត្រូវមានអានុភាពជាង (អធិកភាព)**

១៦. ដោយកត់សម្គាល់ឃើញថាមានការមិនបញ្ចូលការបាត់ខ្លួនដោយបង្ខំក្នុងយុត្តាធិការរបស់ អ.វ.ត.ក នៅក្រោមច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ ដើមបណ្ដឹងរដ្ឋប្បវេណី ព្យាយាមផ្អែកទៅលើ

---

[28] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T សាលក្រម ចុះថ្ងៃទី ២ កញ្ញា ១៩៩៨ កថាខណ្ឌ ៥៨៥។ *សូមមើលផងដែរ* រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Rutaganda,* សំណុំរឿងលេខ ICTR-96-3-T សាលក្រម ចុះថ្ងៃទី ៦ ធ្នូ ១៩៩៩ កថាខណ្ឌ ៧៧។

[29] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង v Kayishema និង Ruzindana* សំណុំរឿងលេខ ICTR-95-1-T សាលក្រម ចុះថ្ងៃទី ២១ ឧសភា ១៩៩៩ កថាខណ្ឌ ១៤៩-១៥០។ *សូមមើលផងដែរ* រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Bagilishema* សំណុំរឿងលេខ, ICTR-95-1A-T សាលក្រម ចុះថ្ងៃទី ៧ មិថុនា ២០០១ កថាខណ្ឌ ៩២។

[30] សៀវភៅរបស់ ANTONIO CASSESE ក្រោមចំណងជើងថា ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (បោះពុម្ពលើកទីពីរ Oxford University Press ២០០៨) ទំព័រ ៤១ ("សៀវភៅរបស់ Cassese")។

[31] រដ្ឋអាជ្ញា ទល់នឹង *Kupreskic et al.*, IT-95-16-T, សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៦៦។

[32] ដូចជើងទំព័រខាងលើ យោងសេចក្ដីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិ 47/133 ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២ និង អនុសញ្ញាអន្តរអាមេរិកកាំង ថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៤។

និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងកិច្ចព្រមព្រៀង ដែល "អនុម័តនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម"[33]។ សន្មតថា អ.វ.ត.ក អាចផ្អែកទៅលើលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលត្រូវបានធ្វើពង្រាងក្នុងឆ្នាំ១៩៩៨ និងបានចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ ដើម្បីធ្វើការពណ៌នាយុត្តាធិការនៃ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តក្នុងឆ្នាំ១៩៧៥-១៩៧៩ ដើមបណ្ដឹងរដ្ឋប្បវេណីលើកទឡ្ហីករណ៍ថា យុត្តាធិការដែលបានចែងនៅក្នុងកិច្ចព្រមព្រៀង ត្រូវមានអធិកភាពលើ យុត្តាធិការដែលមានចែងនៅក្នុងច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ[34]។ ការលើកទឡ្ហីករណ៍នេះមិនត្រឹមត្រូវឡើយ។ មិនមានទំនាស់ជាក់ស្ដែងរវាងច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀងឡើយ ពីព្រោះច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ គឺជាលិខិតុបករណ៍តែមួយគត់ ដែលត្រូវបានកំណត់ឲ្យធ្វើការពណ៌នាអំពីយុត្តាធិការលើបទល្មើស។ វិធីម្យ៉ាងទៀត ប្រសិនបើកិច្ចព្រមព្រៀង និងច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ អាចពណ៌នាអំពីយុត្តាធិការ ហើយពិតជាមានទំនាស់រវាងកិច្ចព្រមព្រៀង និងច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ នោះនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់បង្កើតឲ្យមាន អង្គជំនុំជម្រះវិសាមញ្ញ ត្រូវមានអធិកភាព។

១៧. កិច្ចព្រមព្រៀង ត្រូវបានបង្កើតដើម្បីកំណត់កិច្ចសហប្រតិបត្តិការអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់[35]។ ច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ ត្រូវបានបង្កើតឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់

---

[33] សំណើសុំ កថាខណ្ឌ១០។ លក្ខន្តិកៈទីក្រុងរ៉ូម គឺជាលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ A/CONF.183/9 ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨។

[34] សំណើសុំ កថាខណ្ឌ ១១។

[35] មាត្រា ១ កិច្ចព្រមព្រៀង ។

អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់"[36]។ ពោលគឺ តួនាទីនៃកិច្ចព្រមព្រៀង គឺដើម្បីកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការ សហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា រីឯតួនាទីរបស់ច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីអនុវត្តយ៉ាងពិតប្រាកដថានឹងត្រូវបំពេញឱ្យបានបែបណា រួមមាន ដោយកំណត់ យ៉ាងជាក់លាក់នូវយុត្តាធិការលើបទល្មើស យុត្តាធិការលើអាជ្ញាយុកាល និងយុត្តាធិការលើបុគ្គល នៃ អ.វ.ត.ក។

១៨. មាត្រា ២ នៃកិច្ចព្រមព្រៀងចែងបន្ថែមទៀតថា "កិច្ចព្រមព្រៀងនេះទទួលស្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើបទល្មើស ស្របគ្នាទៅនឹងយុត្តាធិការដូចដែលបានចែងនៅក្នុង [ច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ]"។ លើសពីនេះទៀត មាត្រា ២(២) នៃកិច្ចព្រមព្រៀងចែងថា កិច្ចព្រមព្រៀងនេះត្រូវអនុវត្ត "តាមរយៈ" ច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ។ បទប្បញ្ញត្តិទាំងនេះទំនងជាកំណត់យ៉ាងច្បាស់ តាមរយៈការប្រើពាក្យ "ស្របគ្នា" ថា អ.វ.ត.ក មានយុត្តាធិការលើបទល្មើស ដូចដែលមានចែងនៅក្នុងច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ តែប៉ុណ្ណោះ។ ផ្ទុយទៅនឹងសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី មិនមានទំនាស់ជាក់ស្តែងឡើយ រវាងកិច្ចព្រមព្រៀងនិងច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ។ ទាំងច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះនិងកិច្ចព្រមព្រៀង បង្ហាញថា មានតែច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះដែលធ្វើការពណ៌នាអំពីយុត្តាធិការរបស់ អ.វ.ត.ក។

១៩. ប្រសិនបើ ក.ស.ច.ស ពិចារណាឃើញថា មានទំនាស់រវាងកិច្ចព្រមព្រៀង និងច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ចំពោះយុត្តាធិការ នោះច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញត្រូវមានអធិកភាព។ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តសំណៅដើមនៃច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងឆ្នាំ២០០១[37]។ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងមាត្រា ៥ នៃច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងឆ្នាំ២០០១ គឺដូចគ្នាទៅនឹងនិយមន័យនៅក្នុងសំណៅក្រោយនៃច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ។ ដូច្នេះ នៅពេលដែលកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខារវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣

---

[36] មាត្រា ១ ច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ។

[37] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងអំឡុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិនៅថ្ងៃទី២ ខែមករា ឆ្នាំ២០០១ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ("ច្បាប់បង្កើតឱ្យមានអង្គជំនុំវិសាមញ្ញឆ្នាំ២០០១")។

វាក៏ត្រូវបានអនុវត្តបែបនេះដោយទទួលស្គាល់ដ៏ពេញលេញនៃនិយមន័យនេះ។ មិនមានអ្វីឡើយនៅក្នុងកិច្ចព្រមព្រៀងដែលផ្តល់ជាយោបល់ថា អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាមានបំណងដាក់ជំនួសនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងមាត្រា ៥ នៃច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញឆ្នាំ២០០១[38] ហើយក្រោយមកក៏បានបញ្ជាក់ជាថ្មីម្តងទៀតនៅក្នុងច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញឆ្នាំ២០០៤។ អាចសន្និដ្ឋានបានថា ការយោងទៅលើនិយមន័យនៃឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានបង្កើតឡើងដើម្បីធានាថា មិនមានលក្ខខណ្ឌតម្រូវនៃទំនាក់ទំនងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធឡើយ[39]។ ទំនាក់ទំនងនេះរវាងកិច្ចព្រមព្រៀង និងច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញត្រូវ បានឆ្លុះបញ្ចាំងបន្ថែមទៀតដោយទស្សនៈ ដែលត្រូវបានសម្តែងចេញជាសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជាថា "នៅពេលដែលលក្ខន្តិកៈនៃកិច្ចសហប្រតិបត្តិការ អាចបញ្ជាក់ច្បាស់អំពីភាពខុសគ្នាជាក់លាក់បន្តិចបន្តួចនៅក្នុងច្បាប់ និងពន្យល់នូវសេចក្តីលំអិតជាក់លាក់ វាមិនអាចឱ្យលក្ខន្តិកៈ ទាំងនោះកែប្រែច្បាប់ដែលទើបត្រូវបានប្រកាសឱ្យប្រើបានឡើយ អញ្ចឹងហើយមិនមានអានុភាពលប់លើទេ"[40]។ រាជរដ្ឋាភិបាលកម្ពុជាក៏បានបញ្ជាក់ផងដែរថា មាន ៖

---

[38] Helen Horsington, សាលាក្តីខ្មែរក្រហមកម្ពុជា : ការសន្យារបស់តុលាការកូនកាត់ 5 MELB. J. INT'L L. 462, 473-474 (ឆ្នាំ2004) ។

[39] ដូចជើងទំព័រខាងលើ 474 (2004)។ តាមពិត អ្នកដែលដាក់សំណើនេះ បានលើកទឡ្ហីករណ៍ថា សេចក្តីសំអាងក្នុងមាត្រា ៩ នៃកិច្ចព្រមព្រៀងចំពោះនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ អាចជាកំហុសនៃការរៀបអក្សរបោះពុម្ព ជាពិសេសចំពោះមាត្រា ២ ទទួលស្គាល់ថា អ.វ.ត.ក មានយុត្តាធិការលើបទល្មើស ស្របគ្នាជាមួយនឹងយុត្តាធិការ ដូចដែលមានចែងនៅក្នុងច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ។

[40] លិខិតរបស់រដ្ឋមន្ត្រី សុខ អាន ផ្ញើជូន Hans Corell, អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់, អ្នកប្រឹក្សាផ្នែកច្បាប់ របស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ (http://www.camnet.com.kh/ocm/government/government116.htm)។ រដ្ឋមន្ត្រី សុខ អាន បានបញ្ជាក់បន្ថែមទៀតថា "ខ្ញុំជឿថា ច្បាប់ដែលបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដោយមានការចូលរួមរបស់អន្តរជាតិ និងបំពេញនូវបទដ្ឋានដែលទទួលស្គាល់ជាអន្តរជាតិ តំណាងឱ្យគោលការណ៍ជាមូលដ្ឋានទាំងអស់ ដែលត្រូវបានព្រមព្រៀងរវាងភាគីទាំងពីរ ក្នុងអំឡុងការចចារ"។ សូមអានសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្លើយតបទៅនឹងសេចក្តីប្រកាសអំពីការដកខ្លួនចេញពីកិច្ចចរចារបស់អង្គការសហប្រជាជាតិ ស្តីអំពីការកាត់ទោសខ្មែរក្រហម របស់រដ្ឋមន្ត្រី សុខ អាន ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២ (http://www.camnet.com.kh/ocm/government/government116.htm)។ "ចំណុចសំខាន់ទីពីរ ទាក់ទិនទៅនឹងទំនាក់ទំនងរវាងច្បាប់ប្រទេសកម្ពុជាដែលបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ និងលក្ខន្តិកៈនៃកិច្ចសហប្រតិបត្តិការ ដែលត្រូវបានចុះហត្ថលេខាដោយភាគីទាំងពីរ។ នៅក្នុងលិខិតរបស់ខ្ញុំ ចុះថ្ងៃទី២ ខែវិច្ឆិកា ខ្ញុំបានបញ្ជាក់ថា នៅក្នុងទស្សនរបស់យើង "ច្បាប់ ដែលត្រូវបានអនុម័តដោយ

ភាពខុសគ្នាយ៉ាងច្បាស់រវាងលក្ខណៈ និងគោលបំណងនៃច្បាប់ និងលក្ខន្តិកៈនៃកិច្ចសហប្រតិបត្តិការ។ យើងមិនមានបំណងណាមួយដើម្បីបន្ថយលក្ខន្តិកៈនៃកិច្ចសហប្រតិបត្តិការ "មកត្រឹមជាឯកសារផ្នែករដ្ឋបាល និងបច្ចេកទេស ដែលចំណុះឱ្យច្បាប់ឡើយ" (ប្រើពាក្យរបស់ឯកឧត្តម Hans Corell)។ ហើយវាក៏មិនត្រឹមត្រូវដែរក្នុងការនិយាយ (ដូចដែលនៅក្នុងសំដីរបស់អ្នកនាំពាក្យអគ្គលេខាធិការ) ថា រដ្ឋាភិបាលកម្ពុជា "បានបដិសេធសំណើរបស់អង្គការសហប្រជាជាតិ" ដែលជំនួយគាំទ្ររបស់អង្គការសហប្រជាជាតិ "នឹងត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងប្រទេសកម្ពុជា"។ តាមពិត នេះគឺពិតជាអ្វីដែលយើងប្រមើលឃើញថាជាតួនាទីរបស់លក្ខន្តិកៈនៃកិច្ចសហប្រតិបត្តិការរបស់យើង ដែលជាមូលដ្ឋានធម្មតាមួយសម្រាប់កិច្ចសហប្រតិបត្តិការរវាងរដ្ឋសមាជិក និងអង្គការសហប្រជាជាតិ[41]។

២០. ចំពោះសេចក្តីបញ្ជាក់ទាំងនេះ ដែលពណ៌នាអំពីការយល់ដឹងរបស់រាជរដ្ឋាភិបាលកម្ពុជាអំពីទំនាក់ទំនងរវាងច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង វាមានលក្ខណៈច្បាស់ណាស់ដែលថា ច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញត្រូវមានអធិកភាព ប្រសិនបើទំនាស់កើតមានឡើងរវាងច្បាប់បង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។

**គ. ការបាត់ខ្លួនដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ស្របតាមច្បាប់ប្រទេសកម្ពុជា ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ១៩៧៥-១៩៧៩**

២១. ច្បាប់មួយមិនអាចតាមទម្រង់ប្រតិសកម្មបង្កើតនូវឧក្រិដ្ឋកម្មមួយ ឬទម្រង់នៃការទទួលខុសត្រូវ

---

អង្គនីតិបញ្ញត្តិកម្ពុជា ក្រោមរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា បានកំណត់យុត្តាធិការ និងសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញ ព្រមទាំង សមាសធាតុ រចនាសម្ព័ន្ធរៀបចំ និងនីតិវិធីក្នុងការធ្វើសេចក្តីសម្រេច ដោយឡែក លក្ខន្តិកៈនៃកិច្ចសហប្រតិបត្តិការគឺដើម្បីកំណត់នូវវិធីសាស្ត្រនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ក្នុងការអនុវត្តបទប្បញ្ញត្តទាំងឡាយនៃច្បាប់ ទាក់ទិនទៅនឹងជំនួយផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសបរទេស"។

[41] សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា ឆ្លើយតបទៅនឹងសេចក្តីប្រកាសអំពីការដកខ្លួនចេញពីកិច្ចចរចារបស់អង្គការសហប្រជាជាតិ ស្តីអំពីការកាត់ទោសខ្មែរក្រហម របស់រដ្ឋមន្ត្រី សុខ អាន ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០២ (http://www.camnet.com.kh/ocm/government/government116.htm)។ មានការបញ្ជាក់បន្ថែមទៀតថា "មាត្រា ៤៦ នៃច្បាប់របស់យើង ចែងយ៉ាងច្បាស់ថា បឋមភាពត្រូវបានផ្តល់ឱ្យមានការចូលរួមរបស់អង្គការសហប្រជាជាតិនៅក្នុងដំណើរការនេះ។ វាមានសារៈសំខាន់ណាស់ក្នុងការយល់ថា ច្បាប់ ដែលត្រូវបានអនុម័តដោយអង្គនីតិបញ្ញត្តិរបស់យើង គឺជាលទ្ធផលនៃការចរចាដ៏ស្មុគស្មាញរវាងកម្ពុជា និងអង្គការសហប្រជាជាតិ ហើយនៅក្នុងនោះមានការព្រមព្រៀងគ្នាដ៏សំខាន់ មួយចំនួននៅលើផ្នែករបស់យើង ព្រមទាំងផ្នែករបស់អង្គការសហប្រជាជាតិ"។

ដែលឧក្រិដ្ឋកម្មនោះអាចត្រូវបានប្រព្រឹត្តឡើងឡើយ[42]។ ការធ្វើដូចនេះនឹងរំលោភលើគោលការណ៍គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង (nullum crimen sine lege) ដែលត្រូវបានគាំទ្រ នៅក្នុងលិខិតុបករណ៍សិទ្ធិមនុស្សជាច្រើន[43] នៅក្នុងច្បាប់ប្រទេសកម្ពុជា[44] និងត្រូវបានអនុវត្តនៅតុលាការផ្សេងៗទៀត[45]។ ច្បាប់មួយគ្រាន់តែផ្តល់នូវយុត្តាធិការតុលាការដើម្បីអនុវត្តទម្រង់ នៃការទទួលខុសត្រូវ ដែលត្រូវបានចែងរួចហើយនៅក្នុងច្បាប់សារធាតុ នៅពេលដែលឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់កើតឡើង[46]។ មាត្រា ៥ នៃច្បាប់បង្កើតឱ្យមាន អង្គជំនុំជម្រះវិសាមញ្ញគ្រាន់តែចែងអំពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែល អ.វ.ត.ក មានយុត្តាធិការទៅលើតែប៉ុណ្ណោះ។ វាមិនបានបង្កើតឱ្យមាននូវបទល្មើសសំខាន់នៃឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិត្រូវបានអនុវត្តជាប្រតិសកម្មឡើយ។ ចំពោះការបាត់ខ្លួនដោយបង្ខំ ដែលត្រូវអនុវត្តប្រឆាំងនឹងជនត្រូវចោទនៅក្នុងសំណុំរឿង០០២ ចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ នៅក្នុងឆ្នាំ១៩៧៥-៧៩ វាច្បាស់ជាត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មមួយប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់ប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៥-៧៩។ ករណីនេះវាមិនមែនទេ។

---

[42] គោលការណ៍គ្មានបទល្មើស ប្រសិនបើគ្មានច្បាប់ចែង អនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវ ព្រមទាំងចំពោះឧក្រិដ្ឋកម្មសំខាន់ៗ។ សូមអាន រដ្ឋអាជ្ញា ទល់នឹង *Hadžihasanović & Kubura*, IT-01-47-AR72, សេចក្តីសម្រេលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អិតវ៉ាអំពីយុត្តាធិការ ទាក់ទិនទៅនឹងការទទួលខុសត្រូវក្នុងការចេញបញ្ជា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៣២-៣៥។ រដ្ឋអាជ្ញា ទល់នឹង ***Stakić*, IT-97-24-A,** សាលដីកា ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៦២។

[43] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៥។ អនុសញ្ញាអឺរុបស្តីពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន មាត្រា ៧។ អនុសញ្ញាអន្តរអាមេរិកកាំងស្តីពីសិទ្ធិមនុស្ស មាត្រា ៩។ ធម្មនុញ្ញអាហ្វ្រិក ស្តីពីសិទ្ធិប្រជាជន និងសិទ្ធិមនុស្ស មាត្រា ៧(២)។ លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មាត្រា ២២, ២៤។ អនុសញ្ញាទីក្រុងហ្សឺណែវលើទីបី ឆ្នាំ១៩៤៩ មាត្រា ៩៩។ អនុសញ្ញាទីក្រុងហ្សឺណែវលើកទីបួន ឆ្នាំ១៩៤៩ មាត្រា ៦៧។ មិនមានបដិប្បញ្ញត្តិពីការអនុវត្តសិទ្ធិនេះ អាចទទួលយកបានឡើយក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សូមអាន *Puhk* ទល់នឹង *Estonia*, តុលាការសិទ្ធិមនុស្សអឺរុប, ពាក្យសុំលេខ. 55103/00, សាលក្រម ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ កថាខណ្ឌ ២៤។

[44] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ មាត្រា ៦ កថាខណ្ឌ១។

[45] សូមអានលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មាត្រា ២២។ រដ្ឋអាជ្ញា ទល់នឹង *Vasiljević*, IT-98-32-T, សាលក្រម ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ១៩៣។ រដ្ឋអាជ្ញា ទល់នឹង *Galić*, IT-98-29-T, សាលក្រម ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ ៩៣។

[46] សូមអាន រដ្ឋអាជ្ញា ទល់នឹង *Tadić*, IT-94-01, សេចក្តីសម្រេចលើបណ្តឹងតវ៉ារបស់ក្រុមមេធាវីការពារក្តី ចំពោះបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អិតស្តីពីយុត្តាធិការ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ៩៤។

២២. ដើមបណ្តឹងរដ្ឋប្បវេណី មិនបានបញ្ជាក់នៅក្នុងសំណើដែលថា ការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មក្រោមច្បាប់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៥-៧៩ ឡើយ។ ដូច្នេះ មូលដ្ឋានតែមួយគត់ក្នុងការរួមចំណែកការទទួលខុសត្រូវឧក្រិដ្ឋ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ផ្អែកលើមូលដ្ឋាននេះ នៅក្នុងឆ្នាំ១៩៧៥-៧៩ គឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ[47] អាចត្រូវបានបង្កើតឡើងបានតាមរយៈ (ក) ទម្លាប់អនុវត្តជាទូទៅ និង ស៊ីសង្វាក់គ្នារបស់រដ្ឋ និង (ខ) ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ (opinio juris)[48]។ គោលគំនិតទាំងពីរនេះគឺមានទំនាក់ទំនងគ្នាស្មិតរមួត[49] ហើយអាចជាន់គ្នា[50]។ លើសពីនេះទៀត ទំនៀមទម្លាប់អាចត្រូវបាននិយាយថា ត្រូវបានផ្អែកទៅលើ "ការព្រមព្រៀងដ៏ស្ងៀមស្ងាត់" របស់បណ្តារដ្ឋតាមរយៈការអនុវត្តរបស់ខ្លួន និងការសម្តែងនូវអ្វីដែលរដ្ឋទាំងនោះជឿជាក់ថាមានចងកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុង

---

[47] ច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជាប្រភពមួយនៃច្បាប់អន្តរជាតិ។ វាត្រូវពន្យល់នៅក្នុងមាត្រា ៣៨(១)(ខ) នៃលក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិ ថាជា "ទម្លាប់អន្តរជាតិ សម្រាប់ជាភស្តុតាងនៃមេរៀនទូទៅដែលត្រូវបានទទួលស្គាល់ថាជាច្បាប់"។

[48] មេរៀនរបស់រដ្ឋ គួរតែ "មានលក្ខណៈទូលាយ និងស្មើរតែដូចគ្នាទាំងអស់ នៅក្នុងគោលគំនិតនៃបទប្បញ្ញត្តិដែលត្រូវបានសំអាង"។ *Nicaragua* ទល់នឹង *United States*, (Merits), របាយការណ៍របស់ តុលាការយុត្តិធម៌អន្តរជាតិ ឆ្នាំ១៩៨៦, ("*Nicaragua* ទល់នឹង *United States*") កថាខណ្ឌ ៧៤។ ចំពោះ គោលការណ៍ដែលអំពើមួយក្លាយទៅជាវិធាននៃច្បាប់ (opinion juris) តុលាការយុត្តិធម៌អន្តរជាតិបានអះអាងថា បណ្តារដ្ឋ "ត្រូវតែបានប្រព្រឹត្ត ដូច្នេះ ការអនុវត្តរបស់ខ្លួនគឺជាភស្តុតាង នៃការជឿជាក់ថា ការអនុវត្តនេះ ត្រូវបានតម្រូវជាកាតព្វកិច្ច ដោយអត្ថិភាពនៃវិធាននៃច្បាប់ ដែលត្រូវការការអនុវត្តបែបនោះ"។ *Nicaragua ទល់នឹង United States*, កថាខណ្ឌ ១៤។

[49] សូមអាន IAN BROWNLIE, PRINCIPLES OF PUBLIC INTERNATIONAL LAW 9, (6TH ed. Oxford 2004) ("BROWNLIE") ។ សូមអាន RESTATEMENT OF THE LAW (THIRD) FOREIGN RELATIONS LAW OF THE UNITED STATES § 102(2) (1987), ដែលអនុម័តវិធីសាស្ត្រពីយ៉ាង ចំពោះការបង្កើតនូវ ទម្លាប់អន្តរជាតិ។ *Nicaragua* ទល់នឹង *United States* , កថាខណ្ឌ ២០២។ *North Sea Continental Shelf Cases* ICJ Reports (1969) ("*Continental Shelf*") 3 at 44 បញ្ជាក់ថា "លក្ខណៈជាទម្លាប់ ឬជារឿយៗ នៃមេរៀនរបស់រដ្ឋ គឺមិនគ្រប់គ្រាន់ដើម្បីបង្កើតនូវទម្លាប់ដោយគ្មាន គោលការណ៍ដែលអំពើមួយក្លាយទៅជាវិធាននៃច្បាប់ (opinion juris) ឡើយ"។ *Continental Shelf: Libya* ទល់នឹង *Malta* ICJ Reports (1985) 13 at 29-30: "វាពិត ណាស់ថា លិខិតុបករណ៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺត្រូវបានសំលឹងមើលជាសំខាន់នៅក្នុងការអនុវត្តជាក់ស្តែង និង គោលការណ៍ដែលអំពើមួយក្លាយទៅជាវិធាននៃច្បាប់ (opinion juris) របស់បណ្តារដ្ឋ"។ សូមអាន International Law Association, London Conference, *Statement of Principles Applicable to the Formation of General Customary International Law* (2000)។

[50] សូមអាន P. Haggenmacher, *La doctrine des deux éléments du droit coutumier dans la pratique de la Cour internationale*, 5 Rev. Général du Droit Public International (1986) 114 ។

ចំណោមរដ្ឋទាំងនោះ[51]។ ទម្លាប់អនុវត្តរបស់រដ្ឋមិនចាំបាច់ត្រូវស្របគ្នាទាំងស្រុងឡើយ ប៉ុន្តែកម្រិតដ៏សំខាន់នៃឯកភាពគ្នាតែមួយត្រូវតម្រូវឱ្យមាន[52]។ ភាពស៊ីសង្វាក់គ្នានៃទម្លាប់អនុវត្តរបស់រដ្ឋដែលតម្រូវឱ្យមាន អាចខុសគ្នាអាស្រ័យទៅលើកម្មវត្ថុនៃបណ្តឹងដែលកំពុងដំណើរការ[53]។ វាសម្រាប់ភាគីដែលព្យាយាមពឹងផ្អែកទៅលើវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដើម្បីបង្ហាញអំពីអត្ថិភាពរបស់វិធាននោះ[54]។ ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ (opinio juris) អាចត្រូវ បានចាត់ទុកថាជាការទទួលស្គាល់ដោយបណ្តារដ្ឋថា ទម្លាប់អនុវត្តមួយចំនួនត្រូវ"តម្រូវឱ្យមាន"ចែងក្នុងច្បាប់[55]។ តុលាការយុត្តិធម៌អន្តរជាតិ ស្ទាក់ស្ទើរក្នុងការសន្មតអំពីអត្ថិភាពនៃវិធាននោះ ដោយមិនមានភស្តុតាងផ្ទុយ[56]។ ការពឹងផ្អែកតែទៅលើសេចក្តីសម្រេច និងកិច្ចព្រមព្រៀងអន្តរជាតិ មិនអាចគ្រប់គ្រាន់ក្នុងការបង្កើតឱ្យមាននូវភាពស្របគ្នារវាង ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ (opinio juris) និង ទម្លាប់អនុវត្តរបស់រដ្ឋបានឡើយ[57]។

២៣. អំឡុងពេលដែលវិធានទំនៀមទម្លាប់ត្រូវបានអះអាងថាត្រូវបានគេបង្កើតនោះ គឺមិនមានចែង

---

[51] *The Lotus Case* PCIJ Series. A, no. 10, at p. 18 ("*Lotus Case*") here, តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍បានបញ្ជាក់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជាការសំដែងឆន្ទៈដោយសេរីរបស់បណ្តារដ្ឋ។

[52] *Anglo-Norwegian Fisheries Case* ICJ Reports (1951), 116 កថាខណ្ឌ ១៣១។

[53] ដូចជើងទំព័រខាងលើ។

[54] *Asylum Case (Columbia* ទល់នឹង *Peru)* ICJ Reports (1950), កថាខណ្ឌ២៧៦-៧៧។ រឿងក្តីនេះអាចត្រូវបានចាត់ទុកថា ជាការប្រកាសឈានមុខគេ ដែលត្រូវបានធ្វើឡើងដោយ តុលាការយុត្តិធម៌អន្តរជាតិ ស្តីពីការបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ សូមអាន BROWNLIE, ទំព័រ ៧។ សូមអាន DAVID HARRIS, CASES AND MATERIALS ON INTERNATIONAL LAW( 6TH ed. Oxford 2004), ជំពូក ២; HUGH THIRLWAY, THE SOURCES OF INTERNATIONAL LAW IN MALCOLM EVANS (ED.) INTERNATIONAL LAW, 2ND ED. (Oxford 2006); J. Kammerhofer, *Uncertainty in the Formal Sources of International Law: Customary International Law and Some of its Problems* 15 EUR. J. INT'L L. 523 (2004)។

[55] JL BRIERLY, THE LAW OF NATIONS: AN INTRODUCTION TO THE INTERNATIONAL LAW OF PEACE 61 (6TH ed. Oxford 1963)

[56] រឿងក្តី Lotus នៅចំណុច 28; *Nicaragua* ទល់នឹង *United States*, នៅចំណុច 14 ។

[57] សូមអាន របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ (ឆ្នាំ១៩៩៦) អំពី យោបល់ប្រឹក្សាស្តីអំពីការគំរាមកំហែង ឬការប្រើប្រាស់អាវុធនុយក្លេអ៊ែ ("យោបល់ប្រឹក្សាស្តីអំពីអាវុធនុយក្លេអ៊ែ"), នៅចំណុច ៦៦។ របាយការណ៍របស់តុលាការយុត្តិធម៌អន្តរជាតិ អំពីផលវិបាកផ្នែកច្បាប់សម្រាប់បណ្តារដ្ឋ នៃវត្តមានជាបន្តរបស់អាហ្វ្រិកខាងត្បូង នៅក្នុងប្រទេស ណាមីប៊ី *(South West Africa)* នៅចំណុច ៥០ (ពិភាក្សាអំពីភាពខុសគ្នារវាងសេចក្តីសម្រេចជាប់កាតព្វកិច្ច និងមិនជាប់កាតព្វកិច្ច និងគុណភាពនិយាមដែលទាក់ទងគ្នា)។

ដោយច្បាប់អន្តរជាតិឡើយ[58]។ ទោះបីជាយ៉ាងណាក៏ដោយ រយៈពេលដែលវិធានទំនៀមទម្លាប់ដែលត្រូវបានលើកឡើងថាបានបង្កើតឱ្យមាននោះ កាន់តែតិច នោះតម្រូវការនៃភាពឯកភាពគ្នាតែមួយនៃទម្លាប់អនុវត្តនិង ទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ (opinio juris) កាន់តែតឹងរ៉ឹងថែមទៀត[59]។ ប្រសិនបើមិនមាន "ទម្លាប់អនុវត្តដែលត្រូវបានដោះស្រាយរួច" លេចឡើង ហើយប្រសិនបើបណ្តារដ្ឋមិនបានបង្ហាញនូវ "ការយល់ឃើញ" ណាមួយ ដែលពួកខ្លួនបានប្រតិបត្តិតាមអ្វី ដែលពួកខ្លួនជឿជាក់ថាជាកាតព្វកិច្ចស្របច្បាប់នោះ អត្ថិភាពនៃបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក៏មិនអាចកើតមានឡើយ[60]។

២៤. សំណើសុំនេះ ផ្អែកទៅលើលិខិតុបករណ៍អន្តរជាតិនានា ដើម្បីគាំទ្រដល់ការអះអាងថា ការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[61]។ ការព្រមព្រៀងទាំងអស់នេះ ចុះកាលបរិច្ឆេទក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ មិនមានលិខិតុបករណ៍ណាមួយក្នុងចំណោមលិខិតុបករណ៍ទាំងនេះ បំពេញនូវតម្រូវការទង្វើរបស់រដ្ឋចាំបាច់តាមនីតិរដ្ឋ (opinio juris) ឬទម្លាប់អនុវត្តរបស់រដ្ឋដែលបានបញ្ជាក់ខាងលើឡើយ។ អាស្រ័យហេតុនេះ មិនមានលិខិតុបករណ៍ណាមួយអាចត្រូវបានពឹងផ្អែកទៅលើ ដើម្បីធ្វើយុត្តិកម្មលើសំណើអំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ចំពោះការបាត់ខ្លួនដោយបង្ខំក្នុងឆ្នាំ១៩៧៥-៧៩ ឡើយ។ តាមពិត សំណើនោះទទួល

---

[58] ស្តីអំពីការបង្កើតដ៏ឆាប់រហ័សនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឧទាហរណ៍ សូមអាន យោបល់ផ្ទុយគ្នារបស់ចៅក្រម Tanaka in the *South West Africa Cases*, របាយការណ៍តុលាការយុត្តិធម៌អន្តរជាតិ (1966) 248, នៅចំណុច ២៩១។ R. Jennings, *Recent Developments in the International Law Commission: Its Relation to the Sources of International Law*, 13 I.C.L.Q. 385 (1964) ។

[59] *Continental Shelf*, at 43. យោងតាម តុលាការយុត្តិធម៌អន្តរជាតិ : "ទោះបីជាការកន្លងផុតនៃពេលវេលាដ៏ខ្លី មិនមែនជាឧបសគ្គចាំបាច់ក្នុងការបង្កើតវិធានថ្មីនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយផ្អែកលើមូលដ្ឋាននៃអ្វីដែលជាវិធានអនុសញ្ញាដើមពិតប្រាកដយ៉ាងណាក៏ដោយ តម្រូវការសំខាន់មួយនឹងចាំបាច់ស្ថិតនៅក្នុងរយៈពេលនោះ។ ទោះបីជាអាចមានរយៈពេលខ្លីក៏ដោយ ការអនុវត្តរបស់រដ្ឋ រួមទាំងបណ្តារដ្ឋដែលផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ជាពិសេស គួរតែមានលក្ខណៈទូលាយ និងមានលក្ខណៈដូចគ្នាស្ទើរតែទាំងស្រុង ក្នុងគោលគំនិតនៃបទប្បញ្ញត្តិដែលត្រូវបានសំអាង។ ហើយលើសពីនេះទៀត គួរតែ បានកើតឡើងតាមរបៀបមួយដើម្បីបង្ហាញពីការទទួលស្គាល់ជាទូទៅថា វិធាននៃច្បាប់នៃកាតព្វកិច្ចស្របច្បាប់ត្រូវជាប់ពាក់ព័ន្ធ"។

[60] ដូចដើងទំព័រខាងលើ។

[61] សេចក្តីសម្រេចនៃ [មហាសន្និបាត] 47/133 សេចក្តីប្រកាសស្តីពីការការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ ឯកសារអង្គការសហប្រជាជាតិ A/47/49 ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២។ លក្ខន្តិកៈទីក្រុងរ៉ូម ឆ្នាំ១៩៩៨។ អនុសញ្ញាអន្តរជាតិសម្រាប់ការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ 33 ILM 1429 ឆ្នាំ១៩៩៤។

ស្គាល់ថា "ការធ្វើអោយទៅជាច្បាប់សរសេរចំពោះការបាត់ខ្លួនដោយបង្ខំ ជាឧក្រិដ្ឋកម្មមួយប្រឆាំងមនុស្សជាតិ បានកើតឡើងនៅក្នុងសន្ធិសញ្ញានានាដែលត្រូវបានពង្រាងក្រោយរបបកម្ពុជាប្រជាធិបតេយ្យ"[62]។ សូម្បីតែសាស្ត្រាចារ្យ Antonio Cassese ដែលជាអ្នកការពារការអនុវត្តដ៏តឹងរ៉ឹងនៃការអនុវត្តរបស់រដ្ឋ និងគោលការណ៍ដែលអំពើមួយក្លាយទៅជាវិធាននៃច្បាប់ ដើម្បីបង្កើតវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ[63] អះអាងថា ការបាត់ខ្លួនដោយបង្ខំមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ១៩៧៥-៧៩ ឡើយ[64]។

២៥. ដើមបណ្តឹងរដ្ឋប្បវេណី អះអាងថា ការព្រមព្រៀងទាំងនេះ ដែលចុះកាលបរិច្ឆេទក្រោយរបបកម្ពុជាប្រជាធិបតេយ្យ បានឆ្លុះបញ្ចាំងនូវច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលមានជាយូរណាស់មកហើយ"[65]។ មូលដ្ឋានមួយសម្រាប់សេចក្តីអះអាងនេះ ពោលគឺបទប្បញ្ញត្តិនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលការពារសិទ្ធិរស់រានមានជីវិត និងសេរីភាព និងសន្តិសុខរបស់មនុស្ស[66] គឺមិនទាក់ទងឡើយ។ ការអះអាងនេះ ច្រឡំទៅនឹងច្បាប់សិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយបំផ្លើសយ៉ាងច្រើនអំពីតួនាទីនៃច្បាប់សិទ្ធិមនុស្ស ក្នុងការបង្កើតវិធាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ គោលបំណងនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺដើម្បីបង្កើតនូវសិទ្ធិសម្រាប់ពលរដ្ឋ ទាក់ទិនទៅនឹងបណ្តារដ្ឋ[67]។ គោលបំណង គឺមិនមែនដើម្បីបង្កើតឱ្យមានការទទួលខុសត្រូវឧក្រិដ្ឋជាបុគ្គល ចំពោះ

---

[62] សំណើ កថាខណ្ឌ ៨។

[63] សូមអាន : សំណុំរឿង កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២), បណ្តឹងជំទាស់ របស់ អៀង សារី ទៅលើសាស្ត្រាចារ្យ Antonio Cassese និងសមាជិកដែលត្រូវបានជ្រើសរើស នៃក្រុមប្រឹក្សានៃគណៈកម្មាការនិពន្ធនាយក និងបោះពុម្ពផ្សាយ នៃព្រឹត្តប័ត្ររបស់តុលាការយុត្តធម៌អន្តរជាតិ មិនឱ្យដាក់ជូននូវសារណារបស់ភាគីដែលមិនមែនជាភាគីនៃរឿងក្តី ទៅលើបញ្ហានៃសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាទៅលើដីកាដំណោះស្រាយ ប្រឆាំងនឹង កាំង ហ្គេក អ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៨។

[64] CASSESE ទំព័រ ១១៣។

[65] សំណើ កថាខណ្ឌ ៨។

[66] ដូចដើងទំព័រខាងលើ កថាខណ្ឌ ៨ ជើងទំព័រ ២៥។

[67] សូមអានមាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលចែងថា "រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់រានមានជីវិតនៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន នូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ"។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងអំពីទំនាក់ទំនង រវាងរដ្ឋ និងបុគ្គលទាំងអស់ដែលរស់រានមានជីវិតនៅលើទឹកដីរបស់ខ្លួន មិនមែនទំនាក់ទំនងនៃការទទួលស្គាល់ព្រហ្មទណ្ឌជាបុគ្គលឡើយ។

ការរំលោភបំពានសិទ្ធិទាំងនេះឡើយ[68]។ ការពឹងផ្អែក អាចមិនត្រូវបានស្ថិតនៅលើបទប្បញ្ញត្តិទាំងនេះ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយឡើយ ដើម្បីបង្ហាញថាការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មមួយប្រឆាំងមនុស្សជាតិក្នុងឆ្នាំ១៩៧៥[69]។

២៦. ដើមបណ្តឹងរដ្ឋប្បវេណីក៏បានសំអាងលើការបកស្រាយសាលក្រមតុលាការនូរ៉ាំប៊ើក (Nuremberg Judgement) របស់លោកសាស្ត្រាចារ្យ Cherif Bassiouni ដើម្បីគាំទ្រដល់ការជជែកតវ៉ារបស់ខ្លួនថា បទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការបាត់ខ្លួនដោយបង្ខំឆ្លុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរ-ជាតិដែលមានយូរយារណាស់មកហើយ[70]។ តាមពិត មូលដ្ឋានសំអាងផ្លូវច្បាប់នេះមិនទាក់ទងនឹងអ្វីឡើយ។ លោកសាស្ត្រាចារ្យ Bassiouni គ្រាន់តែពន្យល់ថា តុលាការនូរ៉ាំប៊ើកលើកឡើងថា ប្រសិនបើកិច្ចព្រមព្រៀងមួយកំណត់អំពីការទទួលខុសត្រូវចំពោះបទល្មើសមួយ ដែលបានបង្កើតឡើងយ៉ាងច្បាស់លាស់បែបនេះរួចហើយ ទៅលើចារីប្រព្រឹត្តបទល្មើសពិតប្រាកដដោយច្បាប់វិជ្ជមាននោះ កិច្ចព្រមព្រៀងនេះមិនមានភាពប្រតិសកម្មនោះទេ។ គាត់មិនបានតវ៉ាថា មានការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈផ្ទាល់ខ្លួនចំពោះការបាត់ខ្លួនដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមុនរបបកម្ពុជាប្រជាធិបតេយ្យនោះទេ និងនៅមុនពេលដែលបទឧក្រិដ្ឋនេះត្រូវបានចងក្រង នៅក្នុងកិច្ចព្រមព្រៀងដែលចុះកាលបរិច្ឆេទក្រោយ រយៈពេលនេះយ៉ាងប្រាកដ ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់។ គាត់ក៏មិនបានគាំទ្រដល់ទឡ្ហីករណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថា កិច្ចព្រមព្រៀងក្រោយមកទៀតនោះ អាចជាមូលដ្ឋាននៃការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈផ្ទាល់ខ្លួនដោយគ្មានភាពប្រតិសកម្ម ដោយខ្លួនឯងនោះដែរ ពីព្រោះវាត្រូវតែជាការទទួលខុសត្រូវ "ដែលបង្កើតឡើងដោយច្បាប់វិជ្ជមានទៅលើចារីប្រព្រឹត្តបទល្មើស" នៅពេលដែលបទល្មើសនានាត្រូវបានលើកឡើងថាត្រូវបានប្រព្រឹត្ត។

២៧. ការសំអាងលើច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិក៏ជាការសំអាងខុសដែរ ព្រមទាំងបង្ហាញនូវការភ័ន្តច្រលំថែមទៀតនៅក្នុងសំណើសុំរវាងច្បាប់សារធាតុ និងយុត្តាធិការ។ ច្បាប់លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិដើរតួនាទីពីរ។ ទីមួយ វាពណ៌នាអំពីយុត្តាធិការលើ

---

[68] មិនមានការបញ្ជាក់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលឡើយនៅក្នុង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[69] Kirsten Anderson, តើអនុសញ្ញាអន្តរជាតិសម្រាប់ការពារមនុស្សទាំងអស់ពីការបាត់ខ្លួនដោយបង្ខំ អាចមានប្រសិទ្ធភាពយ៉ាងណា នៅក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ចំពោះអំពើនៃការបាត់ខ្លួនដោយបង្ខំ? [២០០៦] MelbJIL 11។

[70] សំណើ កឋាខណ្ឌទី៨ ជើងទំព័រលេខ២៤។

បទល្មើសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ពោលគឺបទល្មើសដែលអាចត្រូវបានផ្តន្ទាទោសនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ទីពីរ វាបង្កើតនូវបទល្មើសថ្មីៗ។ ច្បាប់លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ អាចបង្កើតនូវបទល្មើសថ្មីៗ ពីព្រោះអនុលោមតាមមាត្រា ១១(១) "តុលាការមានយុត្តាធិការពាក់ព័ន្ធតែនឹងបទល្មើសដែលប្រព្រឹត្តក្រោយពេលច្បាប់លក្ខន្តិកៈនេះ ចូលជាធរមានប៉ុណ្ណោះ"។ ហេតុនេះ ការអនុវត្តបទល្មើសទាំងនេះសម្រាប់រដ្ឋជាសមាជិកនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិចំពោះបទល្មើស ដែលបានលើកឡើងថាបានកើតឡើងក្រោយថ្ងៃទី១ ខែកក្កដា ឆ្នាំ២00២ នោះ មិនរំលោភលើគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen since lege)* នោះទេ[71]។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តបទបញ្ញត្តិព្រហ្មទណ្ឌទាំងនេះឲ្យមានភាពប្រតិសកម្មទៅលើអំពើនានាដែលមានការលើកឡើងថា ត្រូវបានប្រព្រឹត្តនៅឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ពិតជាមានការរំលោភទៅលើគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* ប្រាកដណាស់។

២៨. ដោយហាក់បីដូចជាមានការទទួលស្គាល់ថា អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឆ្នាំ១៩៧៥ ដល់១៩៧៩ ពុំមានការទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការបាត់ខ្លួនដោយបង្ខំទេនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនូវទឡ្ហីករណ៍មួយទៀត: (១) ការបាត់ខ្លួនដោយបង្ខំនាពេលនេះគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ (២) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៥ ដល់១៩៧៩។ ដូច្នេះហើយ (៣) ការបាត់ខ្លួនដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៥ ដល់១៩៧៩។ មានការគិតខុសលើហេតុផលនេះប្រាកដណាស់។ ការយកទឡ្ហីករណ៍នេះទៅធ្វើជាការសន្និដ្ឋានសមហេតុផលនោះ មានន័យថា ការវិវត្តនៃច្បាប់ក្រោយៗមកទៀតដោយបន្ថែមនូវចំនួននៃបទឧក្រិដ្ឋនៅក្នុងប្រភេទពិសេស ដូចជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះនឹងអនុវត្តការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើទាំងនេះដោយមានភាពប្រតិសកម្ម តែក្នុងករណីដែលអំពើនោះស្ថិតនៅក្នុងប្រភេទបទល្មើសពិសេសនេះ ប៉ុណ្ណោះ។ ការណ៍នេះបានធ្វើអោយការការពារនៃ *គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen since lege)* ប្រែទៅជាគ្មាន

[71] គោលបំណងនៃគោលការណ៍គ្រឹះនេះត្រូវបានអះអាងដើម្បី "បង្កើននូវភាពប្រាកដប្រជានៃច្បាប់ ដើម្បីផ្តល់នូវភាពយុត្តិធម៌និងភាពត្រឹមត្រូវដល់ជនជាប់ចោទ ដើម្បីសម្រេចបាននូវការបំពេញតួនាទីដ៏គួរឲ្យញញើតក្នុងការផ្តន្ទាទោសបទល្មើសឲ្យមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភអំណាចនិងពង្រឹងការអនុវត្តនីតិរដ្ឋ"។ សូមមើល M. Cherif Bassiouni សេចក្តីផ្តើមឆ្ពោះទៅច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (ឆ្នាំ២00៣) កឋាខណ្ឌទី១៨0។

ន័យ។

ឃ. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនមែនជា *វិធានអាជ្ញាបញ្ញា* (*jus cogens*) និងគ្មាន *បទដ្ឋានដាច់អហង្ការ* (*peremptory norm*) ក្នុងការផ្តន្ទាទោសឧក្រិដ្ឋកម្ម ទាំងនោះទេ

២៩. ទោះបីជាការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ក៏ដោយ ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលថាការបាត់ខ្លួននោះបានឈានដល់លក្ខខណ្ឌនៃ *វិធានអាជ្ញាបញ្ញា* (*jus cogens*)នោះទេ[72]។ តាមពិតអ្នកស្រាវជ្រាវផ្សេងទៀតបានបដិសេធចំពោះពាក្យថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាបទដ្ឋាន *វិធានអាជ្ញាបញ្ញា* (*jus cogens*)[73]។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ វាមិននាំឱ្យមានភារកិច្ចកាត់ទោសឧក្រិដ្ឋកម្មបែបនេះជាបន្តទៀត ដោយស្វ័យប្រវត្តិនោះទេ។ ការថ្លឹងថ្លែងអំពីមតិយោបល់របស់អ្នកស្រាវជ្រាវបង្ហាញឱ្យឃើញថា ពុំមានភារកិច្ចក្នុងការកាត់ទោសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ[74]។

---

[72] សំណើ កឋាខណ្ឌទី៦-៧ ជើងទំព័រលេខ១៥។

[73] សូមមើល Jill C. Maguire *អំពើរំលោភសេពសន្ថវៈ អនុលោមតាមច្បាប់លក្ខន្តិកៈស្តីពីកំហុសជនបរទេស នៅក្នុង Post-SOSA ទល់នឹង Alvarez-Machain Era*, 13 GEO. MASON L. REV. 935, 968 (ឆ្នាំ២00៥) ដែលសន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនត្រូវបានពិចារណាឃើញថាជាបទដ្ឋានគោលការណ៍គ្រឹះនៃច្បាប់អន្តរជាតិ (jus cogens norms) នោះទេ។

[74] Roman Boed *ផលប៉ះពាល់នៃការលើកលែងទោសក្នុងស្រុកទៅលើលទ្ធភាពនៃរដ្ឋបរទេសក្នុងការផ្តន្ទាទោសចារីប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់ពីបទរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ* 33 Cornell Int'l L.J. 297, 314-18 (ឆ្នាំ២000) (គ្មានភារកិច្ច)។ Claudia Angermaier *តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងការលើកលែងទោសៈ តើតុលាការអាចសម្រុះសម្រួលនូវគំរូនៃភាពយុត្តិធម៌ដែលមានភាពប្រេតិសកម្មដែរទេ?* ផ្នែកមួយស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ១.១៣១ (ឆ្នាំ២00៤) នៅចំណុច ១៤0 (គ្មានភារកិច្ច)។ Michael Scharf *ដកស្រង់ពីសំណុំរឿងនិរទេសៈ ការតាក់តែងអំពីការប្តូរភាពយុត្តិធម៌យកសន្តិភាព* 63 WASH & LEE L. REV 339, 364-367 (ឆ្នាំ២00៦) "ទោះបីជាពុំមានសំណួរថាសហគមន៍អន្តរជាតិបានឯកភាពថា ការហាមឃាត់ប្រឆាំងនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានតម្លៃជាបទដ្ឋានគោលការណ៍គ្រឹះនៃច្បាប់អន្តរជាតិក៏ដោយ ពុំមានន័យថា ភារកិច្ចរួមក្នុងការផ្តន្ទាទោសបានទទួលនូវលក្ខខណ្ឌសមមូលក្នុងពេលដំណាលគ្នានោះទេ។ តាមពិត រាល់ភស្តុតាងទាំងអស់គឺជាភស្តុតាងផ្ទុយ"។ Christine A. E. Bakker ការឈប់លើកលែងទោសទាំងស្រុងនៅក្នុងប្រទេសអាហ្សង់ទីន 3 J. INT'L CRIM. JUST. 1106, 1114 (ឆ្នាំ២00៥) - ដោយមានករណីលើកលែងខ្លះៗ វាពិតណាស់ថាទាំងតុលាការជាតិនិងតុលាការអន្តរជាតិ ក៏ដូចជាអ្នកចេះដឹងច្បាប់ជ្រៅជ្រះជាច្រើនរូប នៅតែស្ទាក់ស្ទើរក្នុងការឯកភាពចំពោះអត្ថិភាពនៃបទដ្ឋានគោលការណ៍គ្រឹះនៃច្បាប់អន្តរជាតិ (*jus cogens* norms) ឬនៅតែបញ្ចេញភាពមន្ទិលសង្ស័យអំពីខ្លឹមសារនិងការអនុវត្តពិតប្រាកដរបស់វា។ សារជាតិគោលការណ៍គ្រឹះអន្តរជាតិនៃការតព្វកិច្ចក្នុងការផ្តន្ទាទោសរាល់ឧក្រិដ្ឋកម្មប្រឆាំងនឹង

៣០. ដោយមានការសន្មតថា មានភារកិច្ចផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ ភារកិច្ចនេះមិនធ្លាក់ទៅលើការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ ប៉ុន្តែធ្លាក់ទៅលើរាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងសង្គមប្រជាធិបតេយ្យ "បទឧក្រិដ្ឋត្រូវបានបង្កើតឡើងតាមរយៈអំណាចនីតិប្រតិបត្តិ។ តុលាការខ្លួនឯងមិនអាចកំណត់សម្រេចអំពីអត្ថិភាពនៃបទល្មើសដែលចាប់ផ្តើមសារជាថ្មី (*de novo*) ដែលមិនបានចែងនៅក្នុងច្បាប់លក្ខន្តិកៈដែលប្រកាសឱ្យប្រើដោយអំណាចនីតិប្រតិបត្តិនោះទេ"[75]។ ដូច្នេះ កាតព្វកិច្ចតាមផ្លូវច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលបានសន្មត មិនដាក់បន្ទុកទៅលើការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ ប៉ុន្តែដាក់បន្ទុកទៅលើរាជរដ្ឋាភិបាលកម្ពុជា។ លើសពីនេះទៀត ដូចដែលអាចឃើញនៅក្នុងយុត្តិ-សាស្ត្ររបស់តុលាការ ICTY ពាក់ព័ន្ធនឹងវិសោធនកម្មនៃការចោទប្រកាន់ ពាក់ព័ន្ធនឹងកាតព្វកិច្ចក្នុងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ព្រមទាំងឧក្រិដ្ឋកម្មសង្គ្រាមដែលបានសន្មតអាចត្រូវបានបដិសេធចោលដោយសារកត្តាផ្សេងៗទៀត។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធចោលសំណើសុំបន្ថែមការចោទប្រកាន់ទៅលើការចោទប្រកាន់ដែលមានស្រាប់ នៅពេលធ្វើបែបនេះនឹង "បណ្តាលឱ្យមានព្យសនកម្មដ៏អយុត្តិធម៌ចំពោះជនជាប់ចោទ"[76]។

**ង. អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនមែនយកមក**

---

មនុស្សជាតិមិនទាន់ត្រូវបានឯកភាពជាទូទៅនៅក្នុងអក្សរសាស្ត្រច្បាប់នៅឡើយទេ។ កត្តាសំខាន់មួយដែលពន្យល់នូវការស្ទាក់ស្ទើរនេះ គឺភាពខ្វះខាតនៃមេរៀនរបស់រដ្ឋក្នុងការគាំទ្រដល់បទដ្ឋានគ្រឹះអន្តរជាតិដែលបានលើកឡើងនេះ។

[75] Ilias Bantekas, *ការផ្ទុះបញ្ហាំងលើប្រភពនិងវិធីមួយចំនួននៃច្បាប់ឧក្រិដ្ឋកម្មនិងមនុស្សធម៌អន្តរជាតិ*, 6 INT'L CRIM. LAW REV. 121, 125 (2006).

[76] *រឿងក្តីរដ្ឋអាជ្ញា តទល់* Delić, ITC-04-83-PT, សេចក្តីសម្រេចលើសារណា នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានដាក់ស្នើបានកែប្រែ និងបណ្តឹងរបស់មេធាវីការពារក្តីចោទប្រកាន់ការផ្តាច់ចេញក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ, ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦, កថាខណ្ឌ៥៣, ទំព័រ៥៧-៧៤។ ការរើសអើងអយុត្តិធម៌នេះអាចសម្តែងឱ្យឃើញដោយខ្លួនឯងតាមរយៈ (១) កង្វះខាតឱកាសគ្រប់គ្រាន់ដើម្បីរៀបចំការការពារដ៏មានប្រសិទ្ធភាព ឬ (២) ការពន្យាពេលមិនមានការកំណត់ចំពោះរយៈពេលនៃដំណើរការនីតិវិធីអង្គបុរេជំនុំជម្រះ កាលបរិច្ឆេទការចាប់ផ្តើមនៃការកាត់សេចក្តី និងរយៈពេលទាំងមូលនៃការកាត់ក្តី។ *សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់* Milan Lukić *និង* Sredoje Lukić, IT-98-32/1-PT, សេចក្តីសម្រេចលើបណ្តឹងរដ្ឋអាជ្ញាស្នើសុំមិនឱ្យកែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែលើកទីពីរ និង លើបណ្តឹងរដ្ឋអាជ្ញាស្នើសុំឱ្យបញ្ចូលសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ 1820 (2008) ជាសម្ភារៈគាំទ្របន្ថែមទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានស្នើសុំកែប្រែលើកទីបី ក៏ដូចជាលើសំណើរបស់ Milian Lukic សុំឱ្យធ្វើការពិចារណាឡើងវិញ ឬការបញ្ជាក់នៃដីការបស់ចៅក្រមអង្គបុរេជំនុំជម្រះ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨, ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨។

**អនុវត្តផ្ទាល់នៅក្នុងតុលាការក្នុងស្រុកនោះទេ**

៣១. ពុំមានអនុសញ្ញាដែលពិចារណាអំពីការទទួលខុសត្រូវផ្ទាល់ខ្លួន ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិធ្វើឡើងដោយបុគ្គលនានានោះទេ។ នៅពេលដែលធម្មនុញ្ញរបស់តុលាការនូរ៉ាំប៊ើក (Nuremberg Charter) ចងក្រងនូវឧក្រិដ្ឋកម្មនេះ[77] មាត្រា ៦(គ) នៃធម្មនុញ្ញដដែលនេះបានចែងច្បាស់លាស់ថា ឧក្រិដ្ឋកម្មទាំងនេះហាក់ដូចជាមិនត្រូវបានរកឃើញនៅក្នុងច្បាប់ប្រចាំរដ្ឋនានាដែលឧក្រិដ្ឋកម្មទាំងនេះបានកើតឡើងនោះទេ។ ហេតុដូច្នេះហើយ មូលដ្ឋានសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតែមួយគត់គឺ ច្បាប់ទំនៀមទម្លាប់អន្តរ-ជាតិ។

៣២. នៅពេលណាដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវបានគេយកធ្វើជាសំអាងនៅក្នុងតុលាការជាតិនោះ តុលាការនោះជាប់កាតព្វកិច្ចពិចារណាថាតើ ប្រព័ន្ធច្បាប់ជាតិត្រូវបានអនុញ្ញាត ឬត្រូវបានចងកាតព្វកិច្ចឲ្យអនុវត្តតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរទេ និងថាតើស្ថិតនៅក្រោមកាលៈទេសៈបែបណា។ នៅពេលដែលគ្មានសេចក្ដីណែនាំជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញ នៅក្នុងបញ្ញត្តិច្បាប់ ឬនៅក្នុងយុត្តិសាស្ត្រជាតិរបស់ខ្លួនទេនោះ តុលាការជាតិមិនជាប់កាតព្វកិច្ចក្នុងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ[78]។ ភាពខុសប្លែកគ្នាជាមូលដ្ឋានរវាងអង្គជំនុំជម្រះវិសាមញ្ញ និងតុលាការ ICTY គឺថា ក្នុងនាមជាតុលាការអន្តរជាតិ តុលាការ ICTY ពិចារណា

---

[77] មាត្រា ៥(គ) នៃធម្មនុញ្ញ IMT ក្នុងការដាក់យុត្តាធិការនៃអង្គជំនុំជម្រះ ប្រសិនបើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺ (មានដូចជា៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងជនស៊ីវិល នៅមុន ឬក្នុងពេលសង្គ្រាម ឬការកាត់សេចក្ដីដោយសំអាងលើបញ្ហានយោបាយ ឬជាតិពន្ធក្នុងការអនុវត្តនៃ/ឬក្នុងការទាក់ទងជាមួយឧក្រិដ្ឋកម្មណាមួយក្នុងយុត្តាធិការនៃអង្គជំនុំជម្រះ ថាតើក្នុងការរំលោភលើច្បាប់ក្នុងស្រុកនៃប្រទេសដែលត្រូវបានប្រព្រឹត្តឬអត់។ មេដឹកនាំ អ្នករៀបចំផែនការណ៍ អ្នកញុះញង់ និងអ្នកសមគំនិតក្នុងការចូលរួមក្នុងការបង្កើត ឬការអនុវត្តន៍នៃផែនការណ៍ទូទៅមួយ ឬការសមគំនិតប្រព្រឹត្តឧកម្មណាមួយកន្លងមក គឺត្រូវទទួលខុសត្រូវចំពោះរាល់អំពើដែលបានប្រព្រឹត្តដោយបុគ្គលណាមួយក្នុងការអនុវត្តន៍ផែនការណ៍នោះ។”

[78] *សូមមើល* Antonio Cassese, International Criminal Law 303 (Oxford University Press 2003) “ជាធម្មតាតុលាការជាតិមិនដំណើការនីតិវិធីរឿងក្ដីលើឧក្រិដ្ឋកម្មអន្តរជាតិទេ ធ្វើតែទៅលើមូលដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺថាប្រសិនបើឧក្រិដ្ឋកម្មមួយមានចែងក្នុងអង្គនៃច្បាប់នោះ។ ជាជំនួស ពួកគេទំនងតម្រូវឲ្យមាន*លក្ខន្តិក*.ជាតិ កំណត់ឧក្រិដ្ឋឧក្រិដ្ឋកម្មនោះ និងទទួលយកយុត្តាធិការតុលាការជាតិ ឬប្រសិនបើសន្ធិសញ្ញាមួយត្រូវបានឲ្យសច្ចាប័នលើបញ្ហានោះដោយរដ្ឋការអនុម័តនៃ *ការអនុវត្តន៍ច្បាប់* អាចឲ្យតុលាការអនុវត្តបទប្បញ្ញត្តិអនុសញ្ញាដែលជាប់ទាក់ទងបានទាំងស្រុង”។

ឃើញថា ខ្លួនអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិបានដោយផ្ទាល់[79]។ ចំណុចនេះមានលក្ខណៈសមហេតុផលទាំងស្រុង។ តុលាការ ICTY មិនមែនជាតុលាការក្នុងស្រុករបស់ប្រទេសយូហ្គោស្លាវីនោះទេ និងមិនត្រូវធ្វើការជ្រើសរើសរវាងទម្រង់នៃការទទួលខុសត្រូវដែលគេឃើញនៅក្នុងច្បាប់ក្នុងស្រុករបស់ប្រទេសយូហ្គោស្លាវី និងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះដែរ។ តុលាការនេះ គ្រាន់តែមានកាតព្វកិច្ចធ្វើការកត់សម្គាល់អំពីច្បាប់ក្នុងស្រុករបស់អតីតយូហ្គោស្លាវីពាក់ព័ន្ធនឹងការផ្តន្ទាទោសតែប៉ុណ្ណោះ[80]។ ផ្ទុយទៅវិញ អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់នៃប្រព័ន្ធច្បាប់ជាតិកម្ពុជា[81]។ អង្គជំនុំជម្រះវិសាមញ្ញអាចអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិបាន ក្នុងករណីដែលមានការអនុញ្ញាតឬចងកាតព្វកិច្ចដោយច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា។

៣៣. ការវិភាគដែលគ្របដណ្តប់លើការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិជាទូទៅ នៅក្នុងប្រទេសកម្ពុជា និងនៅក្នុងប្រទេសផ្សេងទៀត[82] បង្ហាញថា ប្រសិនបើការិយាល័យសហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ការបាត់ខ្លួនដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដោយមិនគិតពីការចងកាតព្វកិច្ចទេនោះ អង្គជំនុំជម្រះវិសាមញ្ញមិនត្រូវបានអនុញ្ញាតឱ្យអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយផ្ទាល់ដោយគ្មានបទបញ្ញត្តិឱ្យអនុវត្តនោះទេ។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចត្រូវបានអនុវត្តផ្ទាល់នៅក្នុងប្រទេសកម្ពុជាបានតែចំណុចដែលពាក់ព័ន្ធនឹងភារកិច្ចច្បាប់រដ្ឋប្បវេណី និងបទល្មើសដែលមិនសំខាន់នានាប៉ុណ្ណោះ ឬក៏ នៅក្នុងករណីដែលច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានអនុវត្តដោយច្បាប់កម្ពុជា។

---

[79] *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់ Tadić*, IT-94-01, សេចក្តីសម្រេចលើបណ្តឹងរបស់មេធាវីការពារក្តី ស្តីពីយុត្តាធិការ, ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៥, កថាខណ្ឌ៦០ ដែលអង្គជំនុំជម្រះសាលាដំបូងថ្លែងថា "ខុសពីភាគីចុះកិច្ចសន្យាលើសន្ធិសញ្ញាទាំងឡាយ តុលាការអន្តរជាតិមិនតម្រូវឱ្យអនុវត្តច្បាប់អនុសញ្ញា ប៉ុន្តែជាជំនួសត្រូវអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ"។

[80] *សូមមើល* វិធាន១០១(ខ)(iii) នៃវិធាននីតិវិធី និងភស្តុតាង ICTY, IT/32/Rev. 42, ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨។

[81] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ០៣),សារណារបស់លោក អៀង សារី អនុលោមតាម សេចក្តីសម្រេចអំពីសំណើជាបន្ទាន់របស់សហមេធាវីសុំការពន្យាពេលសមស្របក្នុងការដាក់សារណាជំទាស់នឹងបញ្ហាយុត្តាធិការ, ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៨, ជើងទំព័រ១៩។

[82] *សូមមើល* ឧបសម្ព័ន្ធ ខ នៃ *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស, សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ស្តីពីការអនុវត្តន៍ទ្រឹស្តី សហកម្មឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក, ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ចំពោះការអត្ថាធិប្បាយដែលបានដាក់បញ្ចូលលើការអនុវត្តន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងតុលាការក្នុងស្រុក។

៣៤. បទបញ្ញត្តិនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដែលការិយាល័យសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថាអាចអនុវត្ត ឬភ្ជាប់ជាមួយច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ គឺមានតែមាត្រា ១ និង ២ ថ្មីប៉ុណ្ណោះ។ មាត្រាទាំងនេះចែងថា អង្គជំនុំជម្រះវិសាមញ្ញត្រូវបានបង្កើតឡើងដើម្បី "នាំយកមកកាត់ទោស... អ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋ និងការរំលោភបំពានធ្ងន់ធ្ងរនៃ... ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ..."[83]។ ទោះបីជាយ៉ាងណាក៏ដោយ បទបញ្ញត្តិនេះ មិនអនុវត្តអនុវត្តចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។ ទីមួយ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះនេះមិនបានចែងច្បាស់លាស់ថា គឺច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលប្រតិបត្តិនេះ ត្រូវយកមកអនុវត្តផ្ទាល់ប្រឆាំងនឹងជនទាំងឡាយ ដែលត្រូវបាននាំយកមកកាត់ទោសចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនោះទេ។ ទីពីរ ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្រោយពេលបទបញ្ញត្តិនេះចូលជាធរមាន បទបញ្ញត្តិដែលប្រតិបត្តិនេះអាចភ្ជាប់ទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិបានតែនៅពេលដែលបទបញ្ញត្តិនោះកើតមាននៅពេលនោះតែប៉ុណ្ណោះ។ ហេតុដូច្នេះ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលប្រកាសឱ្យប្រើនៅឆ្នាំ២០០១ នោះ អាចភ្ជាប់ទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិបានតែចំពោះឧក្រិដ្ឋកម្មទាំងឡាយណាដែលប្រព្រឹត្តឡើងក្រោយឆ្នាំ២០០១នោះតែប៉ុណ្ណោះ[84]។

**ច. អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានធាតុចេតនារើសអើង ហេតុនេះហើយត្រូវបានឆ្លុះបញ្ចាំងតាមរយៈមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ**

៣៥. ដើមបណ្តឹងរដ្ឋប្បវេណី បានសំអាងដោយភ័ន្តច្រលំទៅលើនិយមន័យនៃការបាត់ខ្លួនដោយបង្ខំដែលមាននៅក្នុងច្បាប់លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងផ្តើមចេញមកពីយុត្តិសាស្ត្ររបស់តុលាការ ICTY ក្នុងការជជែកតវ៉ាថា "ចេតនារើសអើងមិនមែនជាធាតុផ្សំដែលកំណត់លក្ខខណ្ឌចំពោះរាល់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ"[85]។ ជាថ្មីម្តងទៀត ប្រភពទាំងអស់បានផ្អែក

---

[83] គូសបញ្ជាក់បន្ថែម។

[84] *Bourterse,* កថាខណ្ឌ៤.៤ និង៤.៧ (តុលាការកំពូលរបស់ប្រទេស Netherland, អង្គជំនុំជម្រះច្បាប់ឧក្រិដ្ឋកម្ម, សេចក្តីសម្រេចនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០១)។ *សូមមើលផងដែរ រឿងក្តី R តទល់ Bow Street metropolitan Stipendiary Magistrate និងអ្នកផ្សេងទៀត, ex parte Pinochet Ugarte (No 3),* ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៩, [2000] 1 AC 147, នៅទំព័រ ២៧៦។

[85] សំណើ, កថាខណ្ឌ ១៦។

លើកាលបរិច្ឆេទក្រោយឆ្នាំ១៩៧៥ ដល់១៩៧៩។ ទំនាស់ដែលបានសន្មតរវាងមាត្រា ៩ នៃកិច្ចព្រម-ព្រៀង និងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ពាក់ព័ន្ធនឹងនិយមន័យនៃការបាត់ខ្លួនដោយបង្ខំថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ះពាល់តែលើយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញតែចំពោះឧក្រិដ្ឋកម្មនេះប៉ុណ្ណោះ។ ចំពោះបញ្ហាដែលការបាត់ខ្លួនដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាផ្នែកនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ១៩៧៥ ដល់១៩៧៩នោះ ពុំមានការកំណត់អំពីធាតុផ្សំនៃបទល្មើស ដែលចុះកាលបរិច្ឆេទក្រោយសកម្មភាពបទល្មើសដែលបានលើកឡើង អាចយកទៅអនុវត្តបានដោយមិនមានការរំលោភលើគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង (nulum crimen sine lege)* នោះទេ។ ជាធម្មតា នៅឆ្នាំ ១៩៧៥ ដល់១៩៧៩ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់បានតម្រូវឱ្យមានចេតនារើសអើង ស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[86]។ ហេតុដូច្នេះ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ មិនផ្លាស់ប្តូរនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្របតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ ប៉ុន្តែផ្ទុះបញ្ចាំងពីបទឧក្រិដ្ឋនោះទៅវិញ។

**ឆ. ជាជម្រើសផ្សេង ការដាក់ព្រំដែនកម្រិតលើយុត្តាធិការដោយអង្គជំនុំជម្រះវិសាមញ្ញទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាការស្របច្បាប់ និងត្រូវតែអនុវត្ត**

៣៦. ដើមបណ្តឹងរដ្ឋប្បវេណី ជជែកតវ៉ាថា លក្ខខណ្ឌកំណត់នៃចេតនារើសអើងសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានកំណត់ព្រំដែននៃយុត្តាធិការដែលជាកម្មវត្ថុរបស់តុលាការយ៉ាងច្បាស់-លាស់[87]។ ចំពោះបញ្ហាថា ការអះអាងបែបនេះត្រឹមត្រូវនោះ វាពិតជាត្រឹមត្រូវតាមច្បាប់ទាំងស្រុង និងបានឆ្លុះបញ្ចាំងពីចេតនារបស់រដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះ និងកិច្ចព្រមព្រៀង ក៏បានកំណត់ព្រំដែនយុត្តាធិការពាក់ព័ន្ធរបស់តុលាការចំពោះបទល្មើសទាំងឡាយណាដែលលើកឡើងថា បានប្រព្រឹត្តនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[88]។ ច្បាប់ទាំងពីរក៏បានកំណត់ព្រំដែនយុត្តាធិការផ្ទាល់ខ្លួនរបស់អង្គជំនុំជម្រះវិសាមញ្ញ ចំពោះ "មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើឧក្រិដ្ឋ និងអំពើ

---

[86] មាត្រា២ នៃលក្ខន្តិកៈ ICTR ទាមទារហេតុជម្រុញឱ្យមានការរើសអើងសម្រាប់រាល់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

[87] សំណើ, កថាខណ្ឌ១៥។

[88] កិច្ចព្រមព្រៀង, មាត្រា១។ ច្បាប់នៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ, មាត្រា២។

រំលោភលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងអនុសញ្ញាអន្តរជាតិនានាដែលប្រទេសកម្ពុជាទទួលស្គាល់"[89]។ ចំណុចនេះផ្ទុះបញ្ចាំងពីការកំណត់ព្រំដែនយុត្តាធិការផ្ទាល់ខ្លួន និងយុត្តាធិការពាក់ព័ន្ធដែលស្រដៀងគ្នានៅតុលាការអន្តរជាតិពិសេស និងនៅតុលាការនានា[90]។

៣៧. អង្គជំនុំជម្រះវិសាមញ្ញ "ដំណើរការជាអង្គភាពឯករាជ្យមួយនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជា"[91]។ ដូចនេះ នៅក្នុងការបង្កើតតុលាការនេះ រាជរដ្ឋាភិបាលកម្ពុជាអាចកំណត់ព្រំដែនទៅលើយុត្តាធិការរបស់តុលាការនេះ រួមទាំងកំណត់ព្រំដែនទៅលើប្រភេទបទល្មើសដែលតុលាការនេះបានបង្កើតឡើងដើម្បីធ្វើការផ្តន្ទាទោស។ វាមិនរំលោភលើកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងក្នុងការកំណត់យុត្តាធិការតាមវិធីនេះដូចដែលបានតវ៉ាដោយដើមបណ្តឹងរដ្ឋប្បវេណីនោះទេ[92] ប៉ុន្តែតាមពិត វាផ្ទុះបញ្ចាំងអំពីកម្មវត្ថុ និងគោលបំណងនេះបានល្អជាង តាមរយៈការផ្តោតទៅលើការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលមានចេតនារើសអើង។

## VI. សន្និដ្ឋាន និងដំណោះស្រាយដែលបានស្នើសុំ

អាស្រ័យហេតុនេះ យោងតាមហេតុផលដែលបានលើកឡើងខាងលើ ក្រុមមេធាវីការពារក្តីសូមស្នើដោយក្តីគោរពដល់សហចៅក្រមស៊ើបអង្កេតសូមមេត្តា៖

---

[89] *ដូចជើងទំព័រខាងលើ។*

[90] មាត្រា៨ នៃ លក្ខន្តិកៈ ICTY កំណត់ព្រំប្រទល់និងភូមិសាស្ត្ររបស់ ICTY ត្រឹម "ទឹកដីនៃអតីតសាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី" និង "អំឡុងពេលចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩១"។ មាត្រា១ នៃលក្ខន្តិកៈ SCSL កំណត់យុត្តាធិការផ្ទាល់ខ្លួន និងភូមិសាស្ត្រ ត្រឹម "ទឹកដីរបស់ប្រទេស Sierra Leone ចាប់តាំងពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៦ មក"។ មាត្រាទី១ នៃលក្ខន្តិកៈ ICTR កំណត់យុត្តាធិការផ្ទាល់ខ្លួន និងភូមិសាស្ត្រ ត្រឹម "ទឹកដីរបស់ប្រទេស រ្វាន់ដា ហើយប្រជាជនរ្វាន់ដា ទទួលខុសត្រូវចំពោះអំពើរំលោភទាំងឡាយដែលបានប្រព្រឹត្តឡើងក្នុងទឹកដីរដ្ឋជិតខាង" និងយុត្តាធិការព្រំប្រទល់ ត្រឹម "រវាងថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៤ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤"។

[91] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ "ឌុច"* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក(អ.ប.ជ០១), សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧, កថាខណ្ឌ១៩។

[92] សំណើ, កថាខណ្ឌ ១៧។

ក. **អនុញ្ញាតតាម**សំណើសុំបន្ថែមទំព័រដែលបានកំណត់ដល់ចំនួន ១៧ទំព័រ។ និង

ខ. **ប្រកាសថា** សំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការបាត់ខ្លួនដោយបង្ខំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ **មិនអាចទទួលយកបាន**។ ឬក៏

គ. **បដិសេធចោល**សំណើសុំបំពេញកិច្ចស៊ើបសួរ។

សូមលោកសហចៅក្រមទទួលយកសេចក្តីឆ្លើយតបនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០០៩

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី